Samanh EBooks

ហួត សេងគៀ

# ធ្វើគ្រូខ្លួនឯង

## វិធីរៀនដោយខ្លួនឯងសម្រាប់ផ្នែកបច្ចេកវិទ្យា



# មាតិកា

សៀវភៅផ្សេងទៀត

ទំព័រដើម

ការបើកផ្លូវដើរ

ផលវិបាកនៃការរៀនក្នុងសាលា

បច្ចេកវិទ្យា ធំធេងណាស់

វិធីរៀនខ្លួនឯង

គ្រូល្អ

# សៀវភៅផ្សេងទៀត

៤ឆ្នាំ

ចរិតឆ្កែ

អាល់ប៊ុមគំនិត ភាគពីរ

ជម្រើសទីពីរ

រើសមកទុកវិញ

រៀនតាមឆាវឆាវ

ជីវិតយើងខ្លីពេក

ទស្សនៈខ្ញុំគេ

ឱ្យគេដេកទៅ

អាល់ប៊ុមគំនិត ភាគពីរ

បោលម្សៀត

inspiremini

រក្សាសិទ្ធិគ្រប់យ៉ាងដោយអ្នកនិពន្ធ ហួត សេងគៀ

ឆ្នាំ ២០១៧

# ទំព័រដើម

ដើម្បីបន្តអាជីពជាអ្នកនិពន្ធដែលគ្មានគេស្គាល់ឈ្មោះនេះទៅមុខទៀត ខ្ញុំត្រូវបង្ខំខ្លួនឯងឲ្យរកប្រធានបទថ្មីមកសរសេរជាសៀវភៅ។ តើអ្នកនិពន្ធប្រភេទណាដែលមិនចេញសៀវភៅថ្មីនោះ? នេះជាសំណួរដែលខ្ញុំដាស់តឿនខ្លួនឯងជាប្រចាំ។ បើខ្ញុំមើលស្នាដៃចាស់ៗរបស់ខ្លួនឯង ហើយគិតថា វាគ្រប់គ្រាន់ហើយដើម្បីមានឈ្មោះជាអ្នកនិពន្ធ ខ្ញុំច្បាស់ជាលែងមានសៀវភៅថ្មីអ្វីទៀតមិនខាន។

សៀវភៅថ្មី មិនដូចរលកថ្មីដែលច្រានរលកចាស់ចោលទេ។ ការសរសេរសៀវភៅថ្មីអាចធ្វើឲ្យខ្ញុំមើលឃើញពីកំហុសដែលមាននៅក្នុងសៀវភៅចាស់ ហើយជួយខ្ញុំអាចកែប្រែបន្ថែមទៅលើស្នាដៃចាស់បាន។ ខ្ញុំស្រលាញ់ស្នាដៃខ្លួនឯង ហើយតែងតែមានបំណងរកពេលដើម្បីកែលំអវាជានិច្ច។

ខ្ញុំមិនមែនជាមនុស្សដែលត្រូវការភាពល្អឥតខ្ចោះទេ ហេតុនេះបានជាសៀវភៅខ្ញុំមួយក្បាលណាក៏មានកំហុសមិនតិចដែរ។ កំហុសទាំងនោះ កើតឡើងដោយអចេតនា។ ខ្ញុំតែងតែជឿថា ខ្ញុំអាចកែវានៅពេលក្រោយបានជានិច្ច ព្រោះខ្ញុំមានសិទ្ធិគ្រប់យ៉ាងទៅលើសៀវភៅ ហេតុនេះបានជា ខ្ញុំមិនដែលទុកសៀវភៅដែលសរសេររួចឲ្យហួសពីមួយអាទិត្យ ដើម្បីបញ្ចេញលក់ ឬដាក់ឲ្យអានលេង។

សៀវភៅ “ធ្វើគ្រូខ្លួនឯង” នេះ ក៏មិនខុសពីសៀវភៅមុនៗរបស់ខ្ញុំដែរ។ វាមានកំហុសហើយខ្ញុំនឹងកែប្រែវានៅពេលក្រោយ។ អ្នកដែលធ្លាប់អានសៀវភៅរបស់ខ្ញុំចប់ពីរ ឬបីក្បាលហើយ អាចនឹងយល់ពីរបៀបដែលខ្ញុំចេញសៀវភៅ ហើយពួកគេនឹងមើលឃើញកំហុសទាំងនោះជាមិនខាន។

គំនិតក្នុងសៀវភៅនេះ កើតឡើងក្រោយពេលខ្ញុំរៀនប្រើកម្មវិធីកាត់តវិដេអូ និងធ្វើវិដេអូ animation ឲ្យក្រុមហ៊ុនដែលជួលខ្ញុំទៅធ្វើការ។ ខ្ញុំលើកឡើងពីវិធីដែលខ្ញុំរៀន

ក្នុងរយៈពេលខ្លី តែអាចយកទៅប្រើបានដោយមិនរញ៉េរញ៉ៃ។ ក្នុងរយៈពេលប្រហែលមួយខែ ខ្ញុំរៀនចេះប្រើកម្មវិធីពីរដែលទាក់ទងនឹងការផលិតវីដេអូ (Adobe Softwares)។ ខ្ញុំរៀនបង្ខំបែបនេះ ព្រោះខាងក្រុមហ៊ុនប្រញាប់។ ខ្ញុំមិនទាន់មានជំនាញទេ តែអាចប្រើបាន។

ដោយសារសៀវភៅនេះកើតឡើងពីអ្វីដែលខ្ញុំរៀន ហេតុនេះវាអាចប្រើបានផលខ្លាំងក្នុងការរៀនជំនាញកុំព្យូទ័រ។ ចំពោះផ្នែកផ្សេង ខ្ញុំមិនអាចធានាបានទេ ទាល់តែមានអ្នកយកទៅសាក ទើបដឹងលទ្ធផល។ វាមិនមែនជាវិធីសាស្រ្តអស្ចារ្យអ្វីទេ តែវាពិតជាប្រើបានផលមែន។

មុននឹងចាប់ផ្ដើមអាន ខ្ញុំសូមបញ្ជាក់ថា យើងមានសមត្ថភាពធ្វើជាគ្រូខ្លួនឯងដូចគ្នា គ្រាន់តែអ្នកខ្លះមិនទាន់ដឹង ឬមិនហ៊ានបង្រៀនខ្លួនឯងប៉ុណ្ណោះ។ ការបង្រៀនខ្លួនឯងអាចងាយជាងបង្រៀនអ្នកដទៃ បើសិនជាយើងដឹងពីក្បួនខ្នាត។ ក្បួនខ្នាតនោះ គឺខ្លួនយើង។ យើងកាន់តែយល់ពីខ្លួនឯង គុណភាពនៃការបង្រៀនរបស់យើង នឹងកាន់តែល្អ។

ហួត សេងគៀ

២៩ ឧសភា ឆ្នាំ២០១៨

# ការបើកផ្លូវដើរ

មនុស្សអវិជ្ជា ត្រូវបានគេចាត់ទុកជាមនុស្សខ្វាក់ ព្រោះទោះបីជាផ្លូវដែលត្រូវដើរនៅនឹងមុខ ក៏គេមិនអាចដឹងថា តើគួរត្រូវទៅខាងណាដែរ។ ផ្លូវដើរមានច្រើន។ បើយើងក្រឡេកមើលទៅកាន់អតីតកាល យើងនឹងមើលឃើញថាចំណេះដឹងពីជំនាន់មុន ត្រូវគេយកមកប្រើឡើងវិញ។ ផ្លូវដើរ មិនដែលរត់ទៅណាទេ ខ្លាចតែយើងទេដែលមិនស្គាល់វា។

យើងមិនចាំបាច់បង្កើតផ្លូវដើរដោយខ្លួនឯងទេ បើសិនជាអ្នកដទៃបង្កើតវារួចទៅហើយ។ យើងអាចខ្ចីផ្លូវដើររបស់គេមកប្រើ ដើម្បីទទួលបានលទ្ធផលប្រហាក់ប្រហែលនឹងគេ។ អ្វីដែលសំខាន់ គឺលទ្ធផល។

ការរៀន ជាការបើកផ្លូវដើរ។ នៅពេលយើងតាំងចិត្តថាមិនចង់ចេះអ្វីផ្សេងទៀត ផ្លូវដើរមួយចំនួននឹងត្រូវលុបបាត់ពីភ្នែករបស់យើង។ យើងអាចពឹងលើចំណេះដឹងបន្តិចបន្តួច និងហួសសម័យដែលនៅជាប់ខ្លួន ដើម្បីដើរលើផ្លូវដដែល ហើយទទួលបានអ្វីដដែលដូចពីមុន។

យើងកាន់តែរៀនបានច្រើន យើងកាន់តែដឹងថា តើយើងគួរដើរផ្លូវណាឲ្យឆាប់ដល់គោលដៅ។ របៀបដែលយើងរៀន គឺជាជម្រើសរបស់យើង។ យើងអាចចាំគេមកបង្រៀនយើង ឬយើងអាចតាំងចិត្តបង្រៀនខ្លួនឯង។ ចំណុចបន្ទាប់នឹងលើពីផលវិបាកនៃការរៀនក្នុងសាលា ដូច្នេះអ្នកដែលចាំគេមកបង្រៀន គួរតែរើសឡើងវិញ។

ការរៀនដោយខ្លួនឯង ជាការពឹងលើខ្លួនឯង ដោះស្រាយបញ្ហាខ្លួនឯង ហើយទទួលផលម្នាក់ឯង។ អ្នកដទៃប្រហែលជាអាចទទួលបានផលខ្លះដែរ តែយើងនឹងរក្សាប្រយោជន៍មួយផ្នែកធំទុកម្នាក់ឯង។

មុនពេលខ្ញុំរៀនពីកម្មវិធីកាត់តវីដេអូ ខ្ញុំមិនយល់ថា តើគេធ្វើវីដេអូតាមរបៀបណាទេ។ ឥលូវ ខ្ញុំដឹងថាគេចាប់ផ្តើមពីណា ហើយខ្ញុំដឹងថាត្រូវរៀនអ្វីបន្តទៀតដើម្បីឲ្យខ្លួនឯងមានជំនាញមួយនេះ។ ខ្ញុំដាក់គោលដៅផ្ទាល់ខ្លួនថា ត្រូវតែរៀនជំនាញថ្មីរាល់ឆ្នាំ ដើម្បីដើរឲ្យទាន់ទីផ្សារការងារ។ ជំនាញក្នុងឆ្នាំនេះរបស់ខ្ញុំ គឺទាក់ទងនឹងវីដេអូ។

ខ្ញុំបើកផ្លូវថ្មីសម្រាប់ឲ្យខ្លួនឯងដើរ ព្រោះពេលខ្ញុំធុញនឹងការងារបច្ចុប្បន្ន ខ្ញុំអាចដាក់ពាក្យឈប់ហើយទៅធ្វើការផ្សេងបាន។ ផ្លូវថ្មីអាចពិបាកជាងផ្លូវពីមុន តែផលតបស្នងរបស់វា ក៏ខុសគ្នាទៅតាមនោះដែរ។ បើខ្ញុំនៅមួយកន្លែងដោយមិនប្រឹងរកផ្លូវផ្សេង មិនយូរទេ ផ្លូវដែលខ្ញុំកំពុងដើរនេះ នឹងត្រូវគេបិទចោល។ ចាំដល់ពេលនោះ គឺយឺតពេលហើយ។ ខ្ញុំធ្វើការក្នុងបច្ចេកវិទ្យា ហេតុនេះខ្ញុំមិនអាចទុកចិត្តអ្វីមួយលើសពីពីរឆ្នាំទេ។ ការផ្លាស់ប្តូរ អាចបង្អត់ក្រពះរបស់ខ្ញុំបាន បើខ្ញុំភ្លេចខ្លួន តែក៏អាចជួយខ្ញុំឲ្យមានក្រពះធំជាងមុនបានដែរ បើខ្ញុំចេះធ្វើការក្នុងផ្នែកនេះ។

មិនថា យើងជឿលើអ្វីទេ ត្រូវតែចាំថា ផ្លូវដើរក្នុងជីវិត ជាទំនួលខុសត្រូវរបស់យើងទាំងស្រុង។ យើងរើសខុស យើងនឹងខាតពេល បើយើងរើសត្រូវ យើងនឹងទទួលបានប្រយោជន៍មុនគេ។ “ធ្វើអ្វីក៏ដោយ ត្រូវតែធ្វើឲ្យបានមុនគេ” ជាសម្តីរបស់មីងខ្ញុំ ក្រោយពេលគាត់រង់ចាំរាប់ឆ្នាំមុននឹងដាច់ចិត្តដាក់ទុករកស៊ីក្នុងកាស៊ីណូ។ វាក៏ជាសម្តីរបស់ខ្ញុំដែលចូលចិត្តប្រើ ពេលខ្ញុំលួចចេញទៅផ្ទះមុនម៉ោងដែរ។

ការរៀន ក៏មិនខុសពីទម្លាប់ស៊ីម៉ោងក្រុមហ៊ុនរបស់ខ្ញុំដែរ។ បើយើងរៀនបានមុនគេ យើងមានឱកាសច្រើនជាងអ្នកដែលរៀនក្រោយ។ អ្នកណាទៅដល់មុន អ្នកនោះបានមុន ហើយប្រហែលជាអាចបិទផ្លូវមិនឲ្យអ្នកមកក្រោយចូលទៀតផង។ សាកគិតទៅមើល បើក្រុមហ៊ុនមួយមានអ្នកដែលអាចធ្វើវីដេអូបាន តើគេនៅត្រូវការជួលមនុស្សផ្សេងមកធ្វើទៀតទេ? ខ្ញុំដឹងថា ក្រុមហ៊ុនមិនខ្លាចសល់លុយច្រើនទេ។

កុំចិត្តអាក្រក់នឹងខ្លួនឯង ត្រូវរៀនដើម្បីបើកផ្លូវ។

# ផលវិបាកនៃការរៀនក្នុងសាលា

សាលារៀន ជាកន្លែងសម្រាប់មនុស្សរៀនពីទំនាក់ទំនង។ យើងជួបពិភាក្សាគ្នា និងស្តាប់គ្នាទៅវិញទៅមក ពីទ្រឹស្តី និងការយល់មិនសព្វជ្រុងរបស់យើង។ គ្មានការពិភាក្សាក្នុងសាលាណា ដែលអាចជួយយើងឲ្យយល់ពីអ្វីមួយបានស៊ីជម្រៅទេ។ យើងអាចនិយាយថា ការរៀនក្នុងសាលា ជារឿងខាតពេលក៏បានដែរ ប៉ុន្តែសូមកុំភ្លេច យើងបានសញ្ញាបត្រដែលបញ្ជាក់ថា យើងជាមនុស្សដែលធ្លាប់ចូលសាលា។ វាក៏ល្អជាងមិនបានអ្វីមកវិញសោះដែរ។

ខ្ញុំរៀនក្នុងសាកលវិទ្យាល័យ៤ឆ្នាំ ដោយគ្មានចេះអ្វីដែលអាចប្រើការកើតសោះ។ ខ្ញុំប្រើពាក្យថា “ប្រើការមិនកើត” ព្រោះអ្វីដែលខ្ញុំរៀន មិនអាចជួយខ្ញុំឲ្យរកការងារបានធ្វើត្រឹមត្រូវ។ ខ្ញុំរៀនចេះច្រើន តែជាចំណេះដឹងដែលហួសសម័យ។ ខ្ញុំមិនអាចបន្ទោសសាលារៀនបានទេ ព្រោះនេះវិធីដែលប្រព័ន្ធអប់រំរបស់យើងបង្កើតឡើង។ គេមិនខ្វល់ថា យើងរៀនចេះ ហើយអាចយកទៅប្រើការបានឬអត់ទេ។ អ្វីដែលគេខ្វល់ គឺភាពល្អមើល។

ផលវិបាកនៃការរៀនក្នុងសាលា មានបីយ៉ាង គឺការចំណាយពេលច្រើន ការរៀនចំណេះដឹងដែលហួសសម័យ និងការខាតលុយ។ ខ្ញុំនឹងលើកយកអំណះអំណាងដែលអ្នករៀនទាំងអស់គ្នាអាចនឹងយល់បាន។ ខ្ញុំមិនវាយប្រហារសាលារៀនទេ ព្រោះវាជាប្រភពចំណេះដឹង តែបើតាមខ្ញុំដឹង ឥលូវនេះ យើងមានអ៊ីនធឺណេតក្នុងដៃហើយ ដូច្នេះតើយើងនៅត្រូវការសាលារៀនដល់កម្រិតណា? យើងនៅតែត្រូវការវាតែប្រហែលមិនត្រូវការដូចពីមុនទៀតទេ។

# ការចំណាយពេលច្រើន

យើងសាកគិតពីពេលវេលាសិន។ ឧទាហរណ៍៖ យើងចង់មានជំនាញផ្នែកអាយធី ដូច្នេះយើងត្រូវប្រើពេល៤ឆ្នាំ ដើម្បីទទួលសញ្ញាបត្រមួយ ដែលទទួលស្គាល់ដោយក្រសួង និងក្រុមហ៊ុននានា។ យើងគ្មានសញ្ញាបត្រ ក៏យើងអាចចូលធ្វើការបានដែរ តែខាងក្រុមហ៊ុននឹងប្រើលេសថា ដោយសារយើងគ្មានបរិញ្ញាបត្រ ដូច្នេះគេពិបាកនឹងឡើងប្រាក់ខែ ឬឲ្យដំណែងធំៗមកយើងណាស់។ យើងប្រាកដជាមិនចង់លឺលេសបែបនេះទេ នៅពេលចរចាជាមួយក្រុមហ៊ុនទេ ដូច្នេះ បើសិនជាអាច គួរណាស់តែមានសញ្ញាបត្រត្រឹមត្រូវ។

ក្នុងពេល៤ឆ្នាំនេះ តើយើងធ្វើអ្វីខ្លះ? យើងចង់ចាប់យកជំនាញអាយធីមែន ប៉ុន្តែយើងមិនមែនរៀនអាយធីគ្រប់មុខនេះទេ។ យើងត្រូវរើសយកមុខវិជ្ជាផ្សេងមករៀនបន្ថែមទៀត ដើម្បីមានចំណេះដឹងទូលាយនៅពេលចេញធ្វើការ។ មូលហេតុនេះ ជាមូលហេតុក្លែងក្លាយ។ មុខវិជ្ជាផ្សេងទៀតដែលយើងត្រូវចំណាយពេលរាប់ខែដើម្បីរៀននោះ មានប្រយោជន៍ស្មើការអានសៀវភៅមួយក្បាល ឬអត្ថបទមួយនៅលើអ៊ីនធឺណេតប៉ុណ្ណោះ។

ឆ្នាំមូលដ្ឋាន ជាឆ្នាំដែលយើងខាតពេលជាងក្នុងសាកលវិទ្យាល័យ ហើយក៏ជាឆ្នាំដែលធ្វើឲ្យខ្ញុំអស់អារម្មណ៍ក្នុងការរៀនដែរ។ ខ្ញុំដឹងថា ក្រសួងអប់រំរៀបចំកម្មវិធីបែបនេះ ដើម្បីជួយសិស្សឲ្យស្វែងយល់ឲ្យបានច្រើនពីជំនាញដទៃ ព្រោះសិស្សខ្លះអាចប្ដូរចិត្តនៅពេលចប់ឆ្នាំទីមួយ។ វាមានប្រយោជន៍ តែវាខាតពេល។ មួយឆ្នាំពេញត្រូវយកមកចោល ទៅលើមុខវិជ្ជាដែលមិនចាំបាច់។ ខ្ញុំចាំថា ខ្ញុំធ្លាប់រៀនថ្នាក់វិទ្យាសាស្ត្រនយោបាយ តែមកដល់ពេលនេះ ខ្ញុំនៅតែគ្មានដឹងខ្យល់អីក្នុងរឿងនយោបាយ ហើយនៅតែត្រូវអ្នកនយោបាយដឹកច្រមុះឲ្យដើរដដែល។ តើមកពីខ្ញុំល្ងង់ម្នាក់ឯង ឬសិស្សដទៃក៏ស្ថិតក្នុងសភាពដូចគ្នាដែរ?

ក្រៅពីមុខវិជ្ជាដែលមិនពាក់ព័ន្ធនឹងជំនាញរបស់យើងហើយ យើងនៅមាន ការពិភាក្សាក្រុម ការធ្វើការងារឲ្យគ្រូ ការប្រឡង និងការប្រឡងសងទៀតបើសិនជាយើងរៀនធ្លាក់។ ក្នុងចំណោមអ្វីដែលខ្ញុំលើកឡើងខាងលើនេះ តើមួយណាដែលមានប្រយោជន៍សម្រាប់យើង?

ការពិភាក្សាក្រុម ជារឿងគ្មានប្រយោជន៍មួយ។ វាជារឿងសប្បាយ ហើយខ្ញុំក៏ចូលចិត្តពិភាក្សាគ្នាជាក្រុមដែរ តែវាខាតពេលខ្លាំងណាស់។ ការងារតូចមួយ នៅពេលដាក់ចូលជាការងារក្រុម វានឹងរីកធំដូចឆាវឆាវរៀបក្បួនសង្គ្រាមភ្លាម។

រាល់ពេលដែលខ្ញុំទៅពិភាក្សាក្រុម ខ្ញុំតែងតែដឹងមុនថា វាគ្មានអ្វីទៅមុខរួចទេ តែខ្ញុំនៅតែទៅដដែល ព្រោះខ្ញុំជានិស្សិត ហេតុនេះត្រូវធ្វើខ្លួនឲ្យដូចជានិស្សិត។ តើអ្នកទាំងអស់គ្នាដឹងថា និស្សិតត្រូវធ្វើខ្លួនដូចម្ដេចទេ? គឺ ធ្វើរឿងអត់ប្រយោជន៍ឲ្យបានច្រើន ព្រោះបើគ្មានរឿងអត់ប្រយោជន៍ទាំងនេះទេ យើងក៏គ្មានអ្វីធ្វើដែរ។

អ្វីដែលខ្ញុំសង្កេតឃើញ គឺ ពេលនៅជានិស្សិត ខ្ញុំឲ្យតម្លៃទៅលើខ្លួនឯងខ្លាំងពេក។ ខ្ញុំគិតថា អ្វីដែលខ្ញុំអាចជួយសង្គម ជួយសាលា ឬជួយអ្នកដទៃ។ តាមពិត វាជាការស្រមៃប៉ុណ្ណោះ។ និស្សិត ជាក្រុមមនុស្សដែលមិនទាន់មានប្រយោជន៍សម្រាប់អ្នកណាទាំងអស់។ សូម្បីតែលែងមានឈ្មោះជានិស្សិតហើយ ក៏យើងមិនប្រាកដថាក្លាយជាមនុស្សមានប្រយោជន៍ដែរ។

ការពិភាក្សាក្រុមដែលលើសពីមួយម៉ោង ជាការពិភាក្សាដែលអូសក្រឡាប៉ុណ្ណោះ។ តើខួរក្បាលយើងដែលទើបនឹងធំនេះ ដឹងច្រើនដល់កម្រិតណារហូតអាចពិភាក្សាគ្នាដល់រាប់ម៉ោងនោះ? អ្វីដែលចេញពីមាត់យើង ជាការស្មានខ្លះ ការប្រឌិតខ្លះ និងមេរៀនពីក្នុងសៀវភៅខ្លះប៉ុណ្ណោះ។ យើងមិនដឹងអ្វីដែលយើងនិយាយចេញមក ជាការពិត ឬមិនពិតទេ។ យើងមានភាពលម្អៀង (bias) លើការគិតរបស់ខ្លួនឯងដែលសូម្បីតែអ្នកវិទ្យាសាស្ត្រជាច្រើនត្រូវប្រឹងប្រែងលុបចោល។ យើងចំណាយពេល

ជុំគ្នាដើម្បីនិយាយអ្វីដែលយើងមិនដឹងច្បាស់ ហើយយើងបោកខ្លួនឯងថា យើងបានរៀនយ៉ាងច្រើនពីការពិភាក្សានេះ។

យើងមិនអាចពង្រីកចំណេះដឹងដោយរបៀបនេះបានទេ ព្រោះនេះជាការរៀនខុស។ ការពិភាក្សាក្រុម ជាតៀមកាហ្វេសម្រាប់និស្សិតប្តូរយោបល់គ្នា ព្រោះគ្មានអ្នកណាចង់ស្តាប់យោបល់និស្សិតទេ។ អ្នកនយោបាយ ម្ចាស់មុខជំនួញ អ្នកកាន់ប្រព័ន្ធឃោសនាផ្សេងៗ ចូលចិត្តធ្វើពុតជាឲ្យតម្លៃទៅលើយោបល់និស្សិត រហូតធ្វើឲ្យនិស្សិតប្រទ្បំថា យោបល់ខ្លួនឯងមានតម្លៃ។

ចំពោះការធ្វើកិច្ចការ និងការប្រឡងវិញ ក៏គ្មានអ្វីចំណេញដល់យើងដែរ។ កិច្ចការផ្ទះជាកិច្ចការដែលគ្រូដាក់ឲ្យ។ គ្រូគិតថា សំណួរនេះគួរឲ្យចាប់អារម្មណ៍ ហេតុនេះគួរតែឲ្យសិស្សយកទៅធ្វើនៅផ្ទះ តែគាត់មិនបានគិតថា តើសិស្សចាប់អារម្មណ៍ដូចគាត់ឬអត់ទេ។ សិស្សមិនរៀនអ្វីច្រើនទេ ពេលដែលគ្មានចំណាប់អារម្មណ៍។

ការប្រឡង រឹតតែខាតពេល។ សាលារៀនហៅការប្រឡងថា ការធ្វើតេស្តសមត្ថភាព តែហេតុអ្វីមិនឲ្យសិស្សបើកមើល? ពេលខ្ញុំចេញធ្វើការ ខ្ញុំបើកមើលឯកសារយោងតែរហូតហ្នឹង ហើយមិនឃើញមានអ្នកណាមកចាប់ខ្ញុំផង។ បើការប្រឡងផ្ទុយពីភាពពិតក្នុងពិភពការងារបែបនេះ តើយើងធ្វើវាដើម្បីអ្វី? យើងរៀនដើម្បីធ្វើការបាន តែសាលារៀន និងពិភពការងារ មិនដើរលើបន្ទាត់ស្របគ្នាសោះ។

បើសិស្សប្រឡងមិនជាប់ ព្រោះខួរក្បាលមិនសូវចាំល្អ ឬជាប់រវល់ធ្វើការមិនបានមើលមេរៀន សិស្សនឹងត្រូវបង់លុយដើម្បីប្រឡងម្តងទៀត។ សាលារៀន បានលុយ តើសិស្សបានអ្វីមកវិញ? គឺខាតពេលប្រឡងម្តងទៀត។ តើសិស្សរៀនបានអ្វីខ្លះក្រោយពេលប្រឡងធ្លាក់? តើសិស្សរៀនបានអ្វីខ្លះពេលប្រលងជាប់វិញ? ខ្ញុំគិតថាដូចជាគ្មានលើសពីអ្វីដែលរៀនក្នុងថ្នាក់ទេ តែហេតុអ្វីបានជាខាតពេលមកប្រឡងម្តងទៀត។ គ្មានអ្នកណាធ្លាប់ប្រាប់ខាងសាលាទេថា “ពេលវេលា ជាមាសប្រាក់”។

# ការរៀនចំណេះដឹងហួសសម័យ

តើវាមានប្រយោជន៍អ្វីដែលយើងរៀនចេះចំណេះដឹងដែលហួសសម័យនោះ? ចំណេះដឹងហួសសម័យ មិនសំដៅដល់ចំណេះដឹងចាស់ៗនោះទេ តែជាអ្វីដែលគេលែងប្រើ ឬមានវិធីផ្សេងដែលគេយកមកប្រើជំនួស។ ចំណេះដឹងចាស់ខ្លះ ល្អជាងអ្វីដែលមានថ្មីទៀតផង។

ឧទាហរណ៍៖ សៀវភៅពុម្ពដែលយើងរៀនត្រូវបានបោះពុម្ពក្នុងឆ្នាំ ២០១៣ ហើយយើងយកមករៀនតាមក្នុងឆ្នាំ ២០១៨។ បើសិនជាវាហួសដល់ ៥ឆ្នាំបែបនេះហើយ ទិន្នន័យដែលមានក្នុងសៀវភៅខ្លះ អាចនឹងប្រើលែងបាន។ បើក្នុងសៀវភៅសរសេរថា ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណេតលើទូរស័ព្ទដៃមានចំនួន១០លាននាក់ ដូច្នេះបើរាប់មកដល់ឆ្នាំ ២០១៨ ចំនួននេះអាចនឹងកើនឡើងខ្លាំងជាងនេះ។ មេរៀនដែលពាក់ព័ន្ធនឹងទិន្នន័យចាស់ ក៏ប្រើមិនត្រូវដែរ។

ការរៀនសរសេរកូដ ក៏មិនខុសគ្នាដែរ។ ខ្ញុំនៅចាំពេលដែលខ្ញុំរៀនធ្វើវេបសាយ មេរៀនដែលគ្រូយកមកបង្រៀន ជាមេរៀនចាស់ ដូច្នេះកូដខ្លះ ក៏ដើរ ខ្លះទៀតក៏មិនដើរ។ ក្រោយមកខ្ញុំរៀនតាមអ៊ីនធឺណេតដោយខ្លួនឯង ទើបដឹងថា គេមានកូដថ្មីច្រើនណាស់ដែលគ្រូមិនបានយកមកបង្រៀន។ ការបង្រៀនរបស់គ្រូ មិនអន់តែ តែមេរៀនចាស់ពេក។ ក្នុងផ្នែកបច្ចេកវិទ្យា ត្រឹមតែ២ឆ្នាំ គឺណាស់ទៅហើយ។

មុននឹងរៀបចំជាមេរៀនឲ្យយើង ខាងលសាលារៀនត្រូវបញ្ជូនមេរៀនទាំងនោះទៅខាងក្រសួងអប់រំសិន ហើយគេមិនចេះតែប្តូរកម្មវិធីសិក្សាតាមចិត្តចង់នោះទេ។ ៥ឆ្នាំ ឬលើសពីនេះ ទើបគេសម្រេចចិត្តថាប្តូរម្តង។ កម្មវិធីសិក្សាដែលប្តូរក្នុងរយៈពេលយូរបែបនេះ មិនអាចតាមទាន់ចំណេះដឹងថ្មីទេ។ អ្នកដែលរៀនក្នុងសាលា តែមិនចេះស្រាវជ្រាវ ជៀសមិនផុតពីការរៀនខុស។

បើសិនជាយើងរៀនប៉ះគ្រូល្អដែលចែករំលែកអ្វីថ្មីក្នុងថ្នាក់ អាចចាត់ទុកថាសំណាង ហើយ។ គ្រូខ្លះ មកបង្រៀនឲ្យតែរួចពីដៃប៉ុណ្ណោះ។ គាត់មិនខ្វល់ពីសិស្សទេ។ យើង មិនអាចពឹងលើគ្រូបានទៀតទេ ក្នុងសម័យនេះ។ មិនមែនថា យើងមិនទុកចិត្ត សមត្ថភាពគាត់ទេ តែយើងគួរតែទុកចិត្តលើសមត្ថភាពរៀនរបស់ខ្លួនឯងវិញ។ សមត្ថភាពរបស់គ្រូ មិនពាក់ព័ន្ធនឹងសមត្ថភាពរបស់យើងទេ។

អ៊ីនធឺណេត ផ្លាស់ប្តូរពិភពលោក។ គ្មានអ្នកណាអាចបដិសេធពីឥទ្ធិពលរបស់វា បានទេ។ ពេលខ្ញុំចូលរៀនសាកលវិទ្យាល័យ អ៊ីនធឺណេត ជាគ្រូរបស់ខ្ញុំ។ ស្ទើរតែ ទាំងអស់នៃជំនាញដែលខ្ញុំមានសព្វថ្ងៃ គឺបានមកពីអ៊ីនធឺណេត។ អ្វីដែលចេញថ្មី នឹងលេចខ្លួនឡើងនៅលើអ៊ីនធឺណេត ហើយខ្ញុំនឹងអាចរៀនវាបានក្នុងពេលដ៏ខ្លី។

ចំណេះដឹងហួសសម័យ មិនមែនថាវាគ្មានតម្លៃទេ ព្រោះយ៉ាងហោចណាស់ក៏យើង ដឹងពីអ្វីដែលគេរកឃើញពីមុនដែរ ប៉ុន្តែវាគ្មានប្រយោជន៍សម្រាប់អនាគត។ យើង រៀនដើម្បីអនាគត ដូច្នេះមានតែចំណេះដឹងថ្មីទេ ដែលអាចរុញយើងទៅមុខបាន។

## ការខាតលុយ

ការរៀនក្នុងសាលា មិនមែនបានមកដោយមិនអស់លុយទេ។ ទោះយើងទទួលបាន អាហារូបករណ៍ ក៏ត្រូវចំណាយលើថ្លៃធ្វើដំណើរ ថ្លៃហូបចុក និងសម្ភារៈសិក្សាដែរ។ លុយត្រូវតែចេញរហូត ព្រោះនេះជាច្បាប់នៃការរស់នៅក្នុងសង្គម។

នៅពេលយើងចូលរៀនក្នុងសាលា យើងក្លាយជាអតិថិជនរបស់វិស័យនេះ តើគេនឹង ធ្វើអ្វីដើម្បីបានលុយពីយើង? គ្មានមុខជំនួញណាដែលបើកហើយមិនរំពឹងបាន ចំណេញទេ។ ចំណុចនេះងាយយល់ ហេតុនេះខ្ញុំមិនចាំបាច់សរសេរច្រើនទេ។

# បច្ចេកវិទ្យា ធំធេងណាស់

បើសិនជាយើងជ្រើសយកផ្លូវដើរ ដោយពឹងលើបច្ចេកវិទ្យា យើងមិនចាំបាច់តែរៀនក្នុងសាលាទេ។ យើងអាចរៀនដោយខ្លួនឯងបាន ដោយចំណាយពេលតិចជាង រៀនចំណេះដឹងថ្មីជាង និងចំណាយលុយតិចជាងទៀតផង។ ការរៀនដោយខ្លួនឯងអាចពិបាក បើសិនជាយើងជាមនុស្សដែលគ្មានវិន័យផ្ទាល់ខ្លួន តែបើយើងលត់ដំមួយថ្ងៃបន្តិច វាក៏មិនមែនជាបញ្ហាអ្វីទៀតដែរ។

មុននឹងចូលដល់វិធីរៀនដោយខ្លួនឯង យើងត្រូវដឹងរឿងមួយជាមុនសិន។ បច្ចេកវិទ្យាគឺធំធេងណាស់។ មិនថា យើងប្រឹងរៀនយ៉ាងណាទេ យើងគ្មានថ្ងៃចេះវាអស់ទេ។ ទោះបីយើងរៀនចេះអស់ក្នុងថ្ងៃនេះ វានឹងបញ្ចេញអ្វីថ្មីមកទៀតនៅថ្ងៃក្រោយ ហើយយើងនឹងត្រូវរៀនវាឡើងវិញម្តងហើយម្តងទៀត។

បច្ចេកវិទ្យា ប្រៀបដូចប្រហោងដ៏ធំមួយដែលគ្មានបាត។ ពេលយើងហក់ចូលទៅហើយ យើងនឹងធ្លាក់ទៅរហូត។ គ្មានអ្នកណាដឹងថា បច្ចេកវិទ្យានឹងរីកចម្រើនដល់ណាទេ។ ខ្ញុំចង់ឲ្យគេរកឃើញពីវិធីដែលអាចធ្វើឲ្យខ្ញុំក្លាយជា Iron man បាន។ ខ្ញុំគ្មានបញ្ហាទេដែលឲ្យគេដាក់គ្រឿងម៉ាស៊ីនចូលក្នុងខ្លួន។

ពេលយើងសម្រេចថារៀនអ្វីមួយ យើងត្រូវដឹងជាមុនថា យើងមិនអាចចេះអ្វីដែលយើងប៉ងរៀនបានទាំងអស់ទេ។ យើងអាចចេះមួយផ្នែកដែលល្មមនឹងអាចឲ្យយើងយកវាទៅប្រើបាន ហើយយើងនឹងត្រូវបន្តរៀនអ្វីថ្មីរហូតដល់អ្វីដែលយើងចេះនោះលែងមានគេប្រើ។ កុំរំពឹងថានឹងចេះអ្វីមួយគ្រប់ដប់ ព្រោះការរំពឹងបែបនេះ បានត្រឹមតែរារាំងយើងមិនឲ្យរៀនអ្វីថ្មីប៉ុណ្ណោះ។

បើចង់រៀនអ្វីក៏ដោយនៅក្នុងបច្ចេកវិទ្យា ត្រូវតែដឹងថាអ្វីគ្រប់គ្រាន់សម្រាប់យើង។ ពេលយើងចេះល្មមហើយ គួរតែផ្អាករៀន ហើយសាកល្បងយកចំណេះដឹងដែល

ទើបនឹងមាននោះទៅអនុវត្ត។ ពេលណាទាល់ ចាំបកមករៀនវិញទៀត។ ការរៀន និងការធ្វើ នៅក្នុងការងារផ្នែកនេះ គឺទាក់ទងគ្នារហូត។ នៅពេលយើងទៅធ្វើការ គ្មានអ្នកណាសួរយើងថា "តើយើងចេះកម្មវិធីនេះ ឬតិចណូឡូជីនេះ មួយរយភាគរយឬអត់ទេ?" តែគេនឹងសួរថា "តើយើងអាចធ្វើការងារនេះបានឬអត់?" ប៉ុណ្ណោះ។ ការងារក្នុងបច្ចេកវិទ្យា ជាការងារដែលផ្តល់ឱកាសដល់អ្នកមិនសូវចេះ។ យើងមិនបាច់ចេះអស់ ក៏មិនអីដែរ សំខាន់ គឺយើងប្រើវាកើតឬអត់។

បើចង់រៀនពីបច្ចេកវិទ្យា ត្រូវគិតដូចបច្ចេកវិទ្យា។ អ្វីក៏ដោយ ក៏អាចអភិវឌ្ឍបន្ថែមបានដែរ។ ថ្ងៃនេះ យើងចេះបីចំណុច ស្អែកយើងអាចរៀនថែមមួយចំណុចទៀតបាន។ យើងអាចបន្ថែមរាល់ថ្ងៃ ដោយមិនបាច់ភ័យថា អស់អ្វីរៀនបន្ត។ បច្ចេកវិទ្យាធំធេងណាស់ យើងមិនអាចប្រៀបស្មើនឹងវាបានទេ តែយើងអាចរៀនវាដើម្បីរស់បាន។

# វិធីរៀនខ្លួនឯង

ដោយសារក្នុងសាលា ខ្ញុំមិនបានរៀនអ្វីដែលអាចជួយខ្ញុំបាន ដូច្នេះខ្ញុំបង្រៀនខ្លួនឯង គ្រប់អ្វីដែលខ្ញុំត្រូវការដើម្បីមានការងារធ្វើ។ អ្វីដែលខ្ញុំមិនធ្លាប់រៀន ខ្ញុំរកចម្លើយនៅលើអ៊ីនធឺណេត។ ការរៀនដោយខ្លួនឯងបែបនេះ អាចពិបាកបន្តិច បើយើងទើបនឹងសាកល្បង តែក្រោយពេលរៀនចេះពីរ ឬបីជំនាញហើយ យើងនឹងដឹងថា ការរៀនខ្លួនឯង ទើបជាការរៀនពិតប្រាកដ។

បើនិយាយឲ្យស្មោះត្រង់ គ្រប់ការរៀនទាំងអស់ សុទ្ធតែកើតចេញពីខ្លួនយើង។ យើងខំខ្លួនឯង ទើបយើងចេះ ប៉ុន្តែនិយមន័យនៃការរៀនខ្លួនឯង គឺការរៀនដែលគ្មានអ្នកដទៃមកចាំត្រួតពិនិត្យ ឬចាំកែកំហុសយើង។ យើងរំលឹកខ្លួនឯង និងរៀបចំពេលសម្រាប់រៀន ហើយយើងក៏អាចដាក់ពិន្ទុឲ្យខ្លួនឯងផងដែរ។ ការរៀនដោយខ្លួនឯងជាជម្រើសល្អសម្រាប់អ្នកចេះរៀន។ “អ្នកចេះរៀន ទើបរៀនចេះ” ជាពាក្យដែលខ្ញុំបានមកពីបងប្រុសម្នាក់ដែលរៀនមិនសូវចេះ តែណែនាំខ្ញុំឲ្យបានចូលរៀនសាកលវិទ្យាល័យ។

ដើម្បីរៀនបាន យើងត្រូវមានអ្នករៀន និងអ្នកបង្រៀន។ ចុះបើអ្នករៀន ក៏ជាយើង ហើយអ្នកបង្រៀនក៏ជាយើងវិញ តើយើងគួរធ្វើរបៀបណា? បើយើងបង្រៀនអ្នកដទៃ យើងអាចត្រៀមខ្លួនជាមុន តែការរៀនខ្លួនឯង មិនទាមទារឲ្យត្រៀមអ្វីច្រើនទេ។ យើងគ្រាន់តែដាក់គូថអង្គុយ ហើយកំណត់ម៉ោងរៀនឲ្យច្បាស់លាស់ យើងនឹងអាចរៀនបាន។

ផលប្រយោជន៍នៃការរៀនខ្លួនឯង គឺយើងអាចរៀនបានគ្រប់ពេល និងគ្រប់ទីកន្លែង។ យើងចង់រៀនយឺតក៏បាន លឿនក៏បាន ចង់ប្រលងក៏បាន មិនប្រឡងក៏បាន។ គ្រប់យ៉ាងស្ថិតលើការសម្រេចចិត្តរបស់យើង។ ការរៀនដែលមានសេរីភាពពេញទំហឹង គឺ

ការរៀនដោយខ្លួនឯង។ សេរីភាពនេះក៏ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់យើងដែរ ទើបអាចមានផល។

ខ្ញុំចាប់ផ្តើមរៀនដោយខ្លួនឯងក្នុងឆ្នាំទីបីនៅសាកលវិទ្យាល័យ ព្រោះខ្ញុំអស់ជំនឿថា នឹងរកលុយបានដោយពឹងលើមេរៀនក្នុងថ្នាក់។ ខ្ញុំលែងខ្វល់ពីមេរៀនក្នុងសាលា ហើយប្រឹងរៀនជំនាញ ក្រាហ្វិចឌីហ្សាញដោយខ្លួនឯង ព្រោះគិតថាវាល្អ និងងាយរកលុយ។ ខ្ញុំរៀនផង និងយកទៅអនុវត្តនៅកន្លែងការងារផង ហេតុនេះខ្ញុំរីកចម្រើនលឿនគួរសមដែរ។ ខាងក្រោមនេះជំហានទាំងបីនៃការរៀនដោយខ្លួនឯង៖

# ទីមួយ ៖ ស្វែងរកបញ្ហា ឬបង្កើតបញ្ហា

នៅក្នុងមុខជំនួញ បញ្ហា គឺជាឱកាសសម្រាប់រកស៊ី។ ពួកគេស្វែងរកបញ្ហាដែលមនុស្សទូទៅមាន រួចក៏រកមធ្យោបាយដោះស្រាយបញ្ហានោះ ដើម្បីលក់យកប្រាក់ចំណេញ។ ទីណាមានបញ្ហា ទីនោះមានមុខជំនួញ។

ពេលយើងរៀន យើងត្រូវចាប់ផ្តើមដោយមានបញ្ហា។ បើគ្មានបញ្ហាច្បាស់លាស់ទេ យើងក៏មិនដឹងថាត្រូវរៀនពីណាទៅណាដែរ ហើយក៏មិនដឹងរៀនដើម្បីអ្វីទៀត។ យើងអាចរកបញ្ហាផ្ទាល់ខ្លួន ដែលយើងចង់សាកដោះស្រាយដោយខ្លួនឯង ឬរកបញ្ហារបស់អ្នកដទៃមកធ្វើក៏បានដែរ។

ឧទាហរណ៍៖ ក្រុមហ៊ុនដែលខ្ញុំកំពុងធ្វើការ ត្រូវការវីដេអូ animation ដើម្បីបង្ហាញពីសេវាកម្មទៅដល់អតិថិជនថ្មីក្នុងរយៈពេលមួយអាទិត្យ។ នេះជាបញ្ហារបស់ក្រុមហ៊ុន ហើយក៏ជាបញ្ហារបស់ខ្ញុំដូចគ្នា ដូច្នេះខ្ញុំត្រូវចាប់ផ្តើមរៀនពីរបៀបបង្កើតវីដេអូ animation ពីដំបូងទៅ ព្រោះខ្ញុំមិនធ្លាប់ធ្វើពីមុនមក។ ដោយសារតែខ្ញុំដឹងថាអ្វីដែលខ្ញុំចង់បាន ហេតុនេះខ្ញុំអាចរកមេរៀនដើម្បីរៀនបាន។ ខ្ញុំមានអ៊ីនធឺណេតប្រើនៅផ្ទះ ហេតុនេះ រឿងងាយៗបែបនេះ មិនពិបាករកទេ។

ការរៀនដោយផ្អែកលើបញ្ហា ជាការរៀនដ៏មានប្រសិទ្ធិភាព ព្រោះមិនថាអ្វីដែលយើងចេះនោះ មានទំហំតូចប៉ុណ្ណាទេ តែវាអាចយកទៅដោះស្រាយបញ្ហាពិតបាន។ វាល្អជាងការរៀនបានច្រើន តែមិនដឹងថាត្រូវប្រើដូចម្តេច។ នៅសាលារៀន មិនសូវមានការអនុវត្តផ្ទាល់ទៅលើបញ្ហាទេ ព្រោះចំនួនសិស្សក្នុងថ្នាក់ច្រើន ពេលវេលាមិនគ្រប់ ហើយគ្រូគិតតែពន្យល់ដោយប្រើស្លាយមេរៀន។ ខ្ញុំមិនថា ស្លាយមេរៀនមិនល្អទេ តែការរៀនរបៀបនេះ មិនត្រូវប្រើក្នុងផ្នែកបច្ចេកវិទ្យា។

បច្ចេកវិទ្យា គឺជាការដោះស្រាយបញ្ហា។ បើយើងចង់ប្រឡូកក្នុងផ្នែកនេះ យើងត្រូវចូលចិត្តបញ្ហា ហើយព្យាយាមរកដំណោះស្រាយ។ ជួនកាលបញ្ហាខ្លះ អាចលើសពីសមត្ថភាពរបស់យើង ដែលយើងអាចនឹងត្រូវបោះបោលក៏មានដែរ។

បើសិនជារកបញ្ហាមិនបានទេ យើងក៏អាចបង្កើតវាឡើងបានដែរ។ អ្នកជំនួញធ្វើបែបនេះគ្រប់ពេល នៅពេលគេចង់បញ្ចេញផលិតផល ឬសេវាកម្មថ្មី។ ឧបមាថា យើងចង់សាកបង្កើតវេបសាយដើម្បីលក់ទំនិញមួយដោយខ្លួនឯង ដូច្នេះយើងអាចរៀនបាន។ យើងគ្មានបំណងបង្កើតវាដើម្បីយកទៅលក់ ឬធ្វើអាជីវកម្មទេ តែយើងចង់បង្កើតវាឡើង ដើម្បីធ្វើជាគោលបំណងនៃការរៀនរបស់យើងប៉ុណ្ណោះ។ បើវាដើរ ក៏ដើរទៅ ហើយបើមិនដើរ ក៏យើងមិនចាំបាច់ពិបាកចិត្តអ្វីដែរ។ យើងកុំភ្លេចថា យើងកំពុងតែរៀន ដូច្នេះភាគរយដែលអាចធ្វើបាន គឺមានមិនច្រើនទេ ប៉ុន្តែវាគ្រាន់បើជាងអ្នកដែលមិនព្រមរៀន។

នៅជុំវិញខ្លួនយើង មានសុទ្ធតែបញ្ហា ដូច្នេះយើងអាចរើសមួយមករៀនដោះស្រាយដោយខ្លួនឯង។ បញ្ហា ជាកម្លាំងជម្រុញរបស់យើង។ ម្យ៉ាងទៀត ការរៀនដោយប្រើបញ្ហាបែបនេះ អាចជួយយើងឲ្យមានអារម្មណ៍ល្អពេលធ្វើបានសម្រេចអ្វីមួយ។ ខ្ញុំធ្វើវីដេអូ animation បានរួចក្នុងរយៈពេលមួយអាទិត្យ ដោយខ្ញុំមិនចេះអ្វីសោះ។ ខ្ញុំមិនសូវពេញចិត្តនឹងវីដេអូនោះប៉ុន្មានទេ ព្រោះវាប្រញាប់ពេក ហេតុនេះមានកន្លែងខ្លះមើលទៅឆ្គង តែខាងក្រុមហ៊ុនអាចយកទៅប្រើបាន។

មុននឹងខ្ញុំរៀនធ្វើ animation ខ្ញុំក៏រៀនកាត់តវីដេអូផងដែរ ព្រោះខាងក្រុមហ៊ុនចង់បានវីដេអូសួស្តីឆ្នាំខ្មែរ ដើម្បីផ្ញើទៅកាន់បុគ្គលិកទាំងអស់។ វីដេអូនោះត្រូវការកែពណ៌ កាត់ចោលកន្លែងមិនចាំបាច់ខ្លះ និងដាក់ចម្រៀងចូលឆ្នាំថែម ហេតុនេះខ្ញុំក៏សម្ងំរៀនកាត់វីដេអូនៅផ្ទះដោយខ្លួនឯង។ ពេលខ្ញុំចេះល្មមហើយ ខ្ញុំយកទៅកាត់នៅក្រុមហ៊ុន ដើម្បីកុំឲ្យគេគិតថា ខ្ញុំស៊ីលុយក្រុមហ៊ុនដោយមិនធ្វើអ្វីសោះ។ ខ្ញុំធ្វើមិនល្អឥតខ្ចោះទេ ព្រោះខ្ញុំទើបនឹងរៀន ប៉ុន្តែវាអាចប្រើការបាន។ សម្រាប់ខ្ញុំ ឲ្យតែប្រើបានគឺគ្រប់គ្រាន់ហើយ។ វាជាការចាប់ផ្តើម ដូច្នេះការរំពឹងឲ្យលើសពីកម្រិតចាប់ផ្តើម ជារឿងល្ងង់បំផុត។

យើងអាចរៀនចេះដោយមិនមានបញ្ហា ប៉ុន្តែការរៀនរបស់យើងនឹងក្លាយជារឿងគួរឲ្យធុញ។ កុំធ្វើគ្រូដែលគួរឲ្យធុញ ជាពិសេសពេលយើងបង្រៀនខ្លួនឯង។

# កំណត់ការចំណាយ

សំណួរដែលយើងត្រូវសួរខ្លួនឯង គឺតើយើងអាចចំណាយលុយប៉ុន្មានទៅលើការរៀនរបស់យើង។ ការរៀនដោយខ្លួនឯង មិនមែនឥតគិតថ្លៃរហូតទេ ព្រោះពេលយើងរៀនកាន់តែច្រើន យើងនឹងមានតម្រូវការដើម្បីតាមទាន់ចំណេះដឹងរបស់យើង។ យើងរស់នៅក្នុងសង្គមដែលគេចាយលុយ ហេតុនេះយើងមិនអាចដកលុយចេញពីអ្វីៗដែលយើងធ្វើបាន។ យើងចំណាយ ដើម្បីបានជំនាញ ត្រលប់មកវិញ។

យើងប្រាកដជាឆ្ងល់ថា អ៊ីនធឺណេតមានមេរៀនឥតគិតថ្លៃច្រើនណាស់ ហើយហេតុអ្វីចាំបាច់ចំណាយលុយទិញ? តាមពិតយើងមិនមែនទិញតែមេរៀនទេ នៅឧបករណ៍សម្រាប់ ឯកសារផ្សេង កម្មវិធី និងសេវាកម្មផ្សេងទៀត។ សូម្បីតែអ៊ីនធឺណេតដែលយើងប្រើ ក៏អស់លុយដែរ។ បើយើងគ្មានលុយសោះ ការរៀន ក៏ពិបាកដែរ។

ពីមុនខ្ញុំឆ្ងល់ថា ហេតុអ្វីកូនអ្នកក្រ មិននាំគ្នារៀនផ្នែកបច្ចេកវិទ្យា ដើម្បីរកការងារធ្វើ? ហេតុអ្វីមិនចេះរៀនដោយខ្លួនឯង? ក្រោយមកទើបខ្ញុំដឹងថា ពួកគេគ្មានលទ្ធភាព សូម្បីតែរៀនដោយខ្លួនឯង។ គ្រាន់តែកុំព្យូទ័រមួយ ក៏ពិបាកនឹងរកលុយទិញទៅហើយ តើអាចរៀនម៉េចនឹងបាន? កុំព្យូទ័រថោកៗ ពិបាករៀនណា មិនអាចប្រើកម្មវិធីធំបាន ហេតុនេះបើទិញមក មានតែទុកចោលប៉ុណ្ណោះ។

យើងចំណាយច្រើនជាងគេទៅលើ គ្រឿងអេឡិចត្រូនិចសម្រាប់រៀន។ កុំព្យូទ័រដែលខ្ញុំប្រើ មានម៉ាស៊ីនធំល្មមដើម្បីកាត់តវីដេអូ និងបង្កើតវីដេអូ animation តូចតាចបាន។ ខ្ញុំត្រូវទិញអេក្រង់កុំព្យូទ័រធំមកជំនួយទៀត ដើម្បីងាយស្រួលមើល ដូច្នេះលុយដែលខ្ញុំចំណាយទៅលើរបស់ទាំងនេះ ក៏មិនតិចដែរ។ បើសិនជាគ្មានលុយ ខ្ញុំប្រហែលជាគ្មានផ្លូវចេះប្រើកម្មវិធីធំៗបែបនេះទេ។ ការងារដែលខ្ញុំធ្វើសព្វថ្ងៃ ជាឈ្នាន់របស់ខ្ញុំនៅថ្ងៃក្រោយ។ ខ្ញុំមើលមិនឃើញថាថ្ងៃក្រោយ ខ្ញុំនឹងត្រូវធ្វើអ្វីទេ ហេតុនេះមានតែត្រៀមខ្លួនប៉ុណ្ណោះ។

យើងអាចគិតរបៀបនេះក៏បានដែរ។ លុយដែលយើងចំណាយទៅលើការរៀនដោយខ្លួនឯង ជាការវិនិយោគរបស់យើង។ បើយើងមិនហ៊ានចំណាយលុយអភិវឌ្ឍខ្លួនឯងទេ តើអ្នកណាហ៊ានចំណាយលុយយកយើងទៅធ្វើការ? សំណួរនេះ ជាសំណួរដែលគេឧស្សាហ៍លើកឡើងនៅក្នុងសិក្ខាសាលាអភិវឌ្ឍខ្លួន។ គេចង់ឲ្យយើងទិញផលិតផលរបស់គេ ហេតុនេះគេចេះតែឃ្លាណាដែលទាក់ទាញចិត្តយើងប៉ុណ្ណោះ។ ការរៀនដោយខ្លួនឯងខុសគ្នា ព្រោះយើងពិតជាធ្វើឲ្យខ្លួនឯងរីកចម្រើនពិតមែន។ យើងមិនបាច់ស្រែកតាមគ្នា មិនបាច់ប្របាច់គ្នា និងមិនបាច់ប្រើពាក្យស្លោកប្រចាំក្រុមអ្វីទាំងអស់។ យើងរៀនចប់ យើងចេះ។

តម្លៃខ្លួនយើង ស្ថិតនៅត្រង់ការវិនិយោគមកលើខ្លួនឯង។ យើងចំណាយពេលកាន់តែច្រើន យើងកាន់តែមានឱកាសហក់ចូលទីផ្សារការងារ។ ការងារមានច្រើន តែការងារល្អ មិនសូវសម្បូរទេ ហេតុនេះទើបយើងប្រឹងឲ្យអស់ចិត្ត ដើម្បីមានការងារល្អ

ក្នុងដៃ។ វាមិនស្អិតស្អេរមែន តែយើងក៏មិនពិបាកក្នុងជីវភាពដែរ។ អ្នកខ្លះមានការងារធ្វើហើយ នៅតែគ្មានជីវភាពធូរធារផង។ ខ្ញុំហ៊ានអះអាងពីចំណុចនេះ ព្រោះខ្ញុំកំពុងធ្វើការងារដែលមិនសូវល្អ ហើយក៏កំពុងពិបាកក្នុងរឿងលុយកាក់ដែរ។

យើងអាចនឹងឆ្ងល់ថា បើចំណាយច្រើនបែបនេះ ម៉េចក៏ថាការរៀនដោយខ្លួនឯងចំណេញជាងការរៀននៅសាលា? វានៅតែតិចជាងក្នុងសាលាដដែលទេ។ កុំភ្លេចបើយើងទៅរៀនសាលា យើងក៏ត្រូវទិញរបស់ទាំងអស់នេះដូចគ្នាដើម្បីរៀន។

យើងចំណាយលុយដើម្បីខ្លួនឯងទេ តើមានអ្វីគួរឲ្យស្តាយ? ខ្ញុំចំណាយលុយទិញមេរៀនដើម្បីកាត់តវីដេអូ។ មួយខែ ខ្ញុំត្រូវបង់លុយឲ្យគេ ១២ដុល្លារដើម្បីបានចូលរៀនមេរៀនដែលគេមាននៅលើវេបសាយ។ ខ្ញុំប្រើ Skillshare និង Udemy។ ពេលត្រូវការសញ្ញាបត្រដើម្បីដាក់ពាក្យធ្វើការ ខ្ញុំរៀនក្នុង Udemy ។ ពេលត្រូវការរៀនអ្វីខ្លីៗ ខ្ញុំរៀនក្នុង Skillshare។ វេបសាយពីរនេះ ជាសាលារៀនដ៏ថោកបំផុតរបស់ខ្ញុំ ហើយនៅក្បែរដៃខ្ញុំទៀត។

ក្រៅពីនេះ ខ្ញុំត្រូវទិញសៀវភៅយកមកអាន តែវាកម្រណាស់ ព្រោះសៀវភៅស៊ីជម្រៅខ្លាំងពេក ហើយខ្ញុំមិនត្រូវការដឹងលម្អិតគ្រប់រឿងដើម្បីធ្វើការបាននោះទេ។ ខ្ញុំរៀនដើម្បីធ្វើការ ដូច្នេះបើកន្លែងខ្លះខ្ញុំមិនចេះ ក៏គ្មានអ្នកណាមកថាអីឲ្យខ្ញុំដែរ។ ឲ្យតែមាន Google អ្វីក៏ខ្ញុំអាចដំណោះស្រាយបានដែរ លើកលែងតែបញ្ហានោះមិនទាន់មានដំណោះស្រាយ។

ដោយសារខ្ញុំមានប្រាក់ខែ ហេតុនេះខ្ញុំមិនបាច់ចំណាយពេលរករបស់ free ទេ។ ធនធានរបស់យើងមានតែពីរទេ គឺពេលវេលា និងលុយ។ បើយើងអាចប្រើលុយដើម្បីចំណេញពេលវេលាបាន គួរតែប្រើទៅ។ យើងអាចរកលុយបានមកវិញ។ ខ្ញុំមិនចង់ខាត ហេតុនេះខ្ញុំទិញភ្លាម ហើយអង្គុយរៀនតែម្តង។ ភាគច្រើន មេរៀនដែលខ្ញុំទិញ មិនលើសពី ២០ដុល្លារទេ។ វាថោកជាងទៅរៀនតាមសាលាឆ្ងាយណាស់។

# ចាប់ផ្តើមពីរូបភាពធំ

យើងជាគ្រូ ហើយក៏ជាសិស្សដែរ ដូច្នេះគ្រប់យ៉ាងស្ថិតលើយើង។ យើងអាចរៀនពីកណ្តាលទៅមុន ហើយទៅរកកន្លែងចាប់ផ្តើមវិញក៏បានដែរ។ យើងរៀនតែអ្វីដែលទាក់ទងនឹងបញ្ហាដែលយើងចង់ដោះស្រាយបានហើយ មិនបាច់រៀនលម្អិតក្នុងពេលតែមួយទេ។ យើងអាចរៀនលម្អិតនៅក្រោយពេលយើងដោះស្រាយបញ្ហាចប់បាន។

សម្រាប់ផ្នែកបច្ចេកវិទ្យា គេមិនរៀនដោយចាប់ផ្តើមឡើងដោយការអានសៀវភៅទេ ព្រោះវាលម្អិតពេក និងធ្វើឲ្យយើងធុញ។ ការធុញនេះសំខាន់ណាស់ ព្រោះយើងអាចបោះចោលការរៀនបាន។ វីដេអូ ជាជម្រើសល្អបំផុតសម្រាប់ការរៀន។ យើងមើលតាមគេ ហើយរៀនធ្វើតាមគេ បន្ទាប់ច្នៃរបស់គេបន្តិចបន្តួច ដើម្បីយកមកដោះស្រាយបញ្ហារបស់យើង។

នៅពេលខ្ញុំចង់ដាក់ caption ចូលទៅក្នុងវីដេអូ ខ្ញុំឆែករកក្នុង Youtube ហើយក៏រៀនតាមគេ។ ខ្ញុំរៀនមិនបាន១០នាទីផង ខ្ញុំក៏អាចធ្វើដោយខ្លួនឯងបាន។ ខ្ញុំប្រើប្រហែលមួយម៉ោង ដើម្បីដាក់ caption ពេញមួយវីដេអូ។ ខ្ញុំមិនទាំងយល់ថា អ្វីជា caption ផង តែខ្ញុំមិនទាន់ខ្វល់ទេ ព្រោះអ្វីដែលខ្ញុំត្រូវខ្វល់នៅពេលនោះ គឺដាក់វាឲ្យរួចដើម្បីបញ្ចប់ការងារ។

ការរៀនលម្អិតក្នុងរឿងអ្វីមួយ ជាកាតព្វកិច្ចសម្រាប់អ្នកជំនាញ មិនមែនសម្រាប់អ្នកទើបនឹងរៀនទេ។ យើងនឹងខាតពេលបើខំប្រឹងស្វែងយល់ពីចំណុចលម្អិតច្រើនពេក ព្រោះយើងមិនបានយកវាមកប្រើ ហើយមិនយូរទេ យើងនឹងភ្លេចអ្វីដែលយើងរៀនមិនខាន។ ការរៀនហើយភ្លេច ជារឿងធម្មតាទេ ហេតុនេះបានជាយើងត្រូវរៀនជាប្រចាំ កុំឲ្យខានយូរពេក។

# គ្រូល្អ

បើសិនជាដាក់ចិត្តធ្វើជាគ្រូខ្លួនឯងទៅហើយ ត្រូវធ្វើជាគ្រូល្អម្នាក់។ ខាងក្រោមនេះជាអ្វីដែលខ្ញុំគិតថា គ្រូដែលបង្រៀនបានល្អគួរតែមាន ៖

## បង្រៀនសិស្សឲ្យចេះឆ្ងល់

ការឆ្ងល់ ជាប្រភពនៃចំណេះដឹង។ បើគ្មានការឆ្ងល់ទេ យើងក៏មិនចង់ធ្វើអ្វីដែរ។ គ្រូល្អត្រូវពូកែលើកជាសំណួរដែលធ្វើឲ្យសិស្សឆ្ងល់ ហើយទុកពេលឲ្យសិស្សស្វែងរកចម្លើយដោយខ្លួនឯង។ ការបង្កើតទម្លាប់ឲ្យសិស្សចូលចិត្តការស្រាវជ្រាវ ជាកត្តាជោគជ័យក្នុងការរៀនសូត្រ។ អ្នករៀនណាដែលមិនចេះស្រាវជ្រាវ ប្រៀបដូចជាអ្នកសិល្បៈដែលមិនចេះអែបអបគេ។ ការប្រៀបធៀបរបស់ខ្ញុំប្រហែលជាមិនត្រូវទេ តែខ្ញុំមិនខ្វល់ទេ ព្រោះវាមិនមែនជាពេលដែលត្រូវខ្វល់។

ការឆ្ងល់ នាំសិស្សឲ្យចំណាយពេលគិត។ ការគិត នឹងធ្វើឲ្យសិស្សដឹងថា ខ្លួនឯងក៏មានសមត្ថភាពធ្វើអ្វីដោយខ្លួនឯងដែរ។ ធ្វើជាគ្រូ កុំខ្លាចសិស្សចេះគិត ព្រោះនោះជាជោគជ័យសម្រាប់គ្រូហើយ។ ការបង្រៀនសិស្សឲ្យចេះគិតដោយខ្លួនឯង ធំជាងការបង្រៀនសិស្សឲ្យបានសញ្ញាបត្រទៀត។

## បង្រៀនសិស្សឲ្យហ៊ានសាកល្បង

បើមិនធ្វើដោយខ្លួនឯង តើម៉េចនឹងអាចចេះ? បើខ្ញុំមិនកាត់វីដេអូដោយខ្លួនឯង តើខ្ញុំអាចចេះបានដែរទេ? យើងអាចមើលវីដេអូរបស់អ្នកដទៃធ្វើអ្វីមួយរាប់ម៉ោង តែបើយើងមិនធ្វើតាមគេ កុំសង្ឃឹមថាយើងបានរៀនអ្វីឲ្យសោះ។ ការអង្គុយមើល និងការធ្វើតាម ផ្តល់ផលខុសគ្នា។ យើងរៀនផង និងធ្វើផងក្នុងពេលតែមួយបែបនេះ ជៀស

មិនផុតពីមានកំហុសទេ តែកំហុសសម្រាប់អ្នករៀន ជារឿងល្អ។ យើងដឹងថាអ្វីដែលយើងធ្វើមិនត្រូវ បន្ទាប់មកយើងនឹងដឹងថាអ្វីត្រូវ។

ក្នុងការរៀន យើងត្រូវដឹងខុសមុន ទើបរកត្រូវឃើញ។ នៅពេលខ្ញុំរៀនធ្វើវេបសាយដំបូង ខ្ញុំសរសេរកូដខុសរាប់មិនអស់។ កំហុសរបស់ខ្ញុំ នឹងប្រាប់ខ្ញុំថា តើអ្វីដែលធ្វើឲ្យវាមិនដើរ ហើយតើវិធីសាស្ត្រអ្វីដែលខ្ញុំអាចយកមកប្រើបាន។ បើខ្ញុំមិនសរសេរខុស ខ្ញុំក៏មិនដឹងថា សរសេរបែបហ្នឹងវាខុសនឹងក្បួនខ្នាតគេដែរ។

ការរៀនចោល ដោយគ្មានការអនុវត្ត ជារឿងខាតពេល។ បើយើងមិនចង់ធ្វើទេ កុំចំណាយពេលរៀន។ អ្នករៀន ជាអ្នកហ៊ានសាកល្បង។ អ្នកហ៊ានសាកល្បង ជាអ្នកចេះ។ រឿងល្អមួយទាក់ទងនឹងការសាកល្បង គឺ មិនថាយើងខុសប៉ុន្មានដងទេ យើងនៅតែគ្រាន់បើជាងអ្នកមិនរៀន និងអ្នកមិនហ៊ានធ្វើជានិច្ច។ យើងទៅមុខ គេនៅមួយកន្លែង។ តើត្រង់ណាដែលថាមិនល្អ?

## បង្រៀនសិស្សឲ្យចេះបង្រៀនគេវិញ

គ្រូ ជាអ្នកដឹកនាំ។ គ្រូដឹកនាំសិស្សចេញពីភាពល្ងង់ខ្លៅ ទៅរកភាពចេះដឹង និងមានប្រយោជន៍។ កាតព្វកិច្ចរបស់អ្នកដឹកនាំ គឺបណ្តុះអ្នកដឹកនាំថ្មីបន្តទៀត។ គ្រូក៏ដូចគ្នាដែរ ត្រូវបណ្តុះគ្រូជំនាន់ក្រោយទៀត ដើម្បីចែកចាយការចេះដឹងរបស់ខ្លួន។

ពេលបង្រៀនសិស្ស ត្រូវបង្រៀនឲ្យច្បាស់ ដើម្បីឲ្យសិស្សដឹងថា តើការពន្យល់ល្អមានលក្ខណៈដូចម្តេច? យើងអាចបង្ហើបប្រាប់សិស្សថា ការបង្រៀន ជាគន្លឹះនៃការរៀន។ បើយើងចេះបង្រៀន យើងក៏ចេះរៀនដូចគ្នា។ខ្ញុំធ្លាប់បង្រៀនក្រាហ្វិចឌីហ្សាញ ដូច្នេះវាមិនចម្លែកទេដែលខ្ញុំអាចបង្រៀនខ្លួនឯងបាន។

គ្រូអាយធីនៅសាលាខ្ញុំម្នាក់ ចូលចិត្តថតជាវីដេអូនៅពេលគាត់បង្រៀន ឬពន្យល់ពីគន្លឹះចាំបាច់ណាមួយ។ នៅពេលចប់ម៉ោង សិស្សដែលមិនទាន់យល់ច្បាស់ អាចមក

កូពីយកវីដេអូនោះ ទៅមើលឡើងវិញបាន។ សិស្សមានឱកាសដើម្បីយកវីដេអូនោះ ទៅរៀនដោយខ្លួនឯង។ ពួកគេក៏ឃើញពីវិធីបង្រៀនដ៏ល្អមួយដែរ គឺការថតជាវីដេអូទុក។ គ្រូជាច្រើនបានថតវីដេអូដែលខ្លួនបង្រៀនក្នុងថ្នាក់ ហើយដាក់នៅលើ youtube ឬវេបសាយផ្ទាល់ខ្លួនរបស់ពួកគាត់ ដើម្បីបើកឱកាសឲ្យអ្នកដែលគ្មានលទ្ធភាពចូលសាលា បានរៀនដូចគេដែរ។

ការបង្រៀន ជាការចែករំលែកចំណេះដឹង ដោយមានគោលបំណងច្បាស់លាស់។ បើសិនជាធ្វើបានល្អ នឹងក្លាយជាគម្រូដល់អ្នករៀនជំនាន់ក្រោយឲ្យស្រលាញ់ការចែករំលែកបែបនេះបន្តទៀត។

# ដល់វេនយើងធ្វើគ្រូល្អ

ឥលូវយកលក្ខណៈទាំងបីខាងលើមកធ្វើដោយខ្លួនឯង។ យើងត្រូវបង្រៀនខ្លួនឯងឲ្យឆ្ងល់ ឲ្យហ៊ានសាកល្បង និងឲ្យចេះបង្រៀនអ្នកដទៃ។ បើយើងជាគ្រូល្អ ការរៀនរបស់យើងក៏រលូនទៅមុខដែរ។

*"ការបង្រៀនខ្លួនឯង នឹងធ្វើឲ្យយើងចេះគោរពខ្លួនឯង"*

**បើសិនជាមានចំណាប់អារម្មណ៍ អាចទាក់ទងទិញសៀវភៅផ្សេងទៀត**
**តាមរយៈលេខទូរស័ព្ទ ០១៥ ២១ ៨៨ ៣២**